ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤០
ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩
សាលដីកា
លេខ: ១៥ (I)
ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រមរបាយការណ៍

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២០២ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភរិយា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៧ សស ក្រ.VII "ធ" ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន៖

**ជនត្រូវចោទ:** ឈ្មោះ [redacted] ប្ញារ៉ា ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរអ្នកសារពត៌មានកំរិតវប្បធម៌បរិញ្ញាបត្រគ្រប់គ្រង ។ ទីកន្លែងកំណើតនៅភូមិ១៦ ឃុំកំពង់លែង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ទីលំនៅសព្វថ្ងៃ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]

Scanned with CamScanner

(ស) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ទោសពីមុនគ្មាន ។ ក្រៅឃុំ (ចុងបណ្ដឹងសាទុក្ខ)

មេធាវីការពារលោក [redacted] ចណ្ណារិទ្ធិ

ត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិចុង ឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម កាលអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភារម្យ ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។(ដើមបណ្ដឹងសាទុក្ខ)

មានមេធាវីការពារលោក [redacted] ស៊ីដាណា

**អំពីអង្គហេតុ**

កាលអំឡុងឆ្នាំ២០១៨ នៅចំណុចភូមិចុង ឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម មានករណី ឆបោក មួយកើតឡើង ដែលបង្កដោយជនសង្ស័យឈ្មោះ [redacted] បូរ៉ា បានធ្វើសកម្មភាពប្រើឧបាយកលទុច្ចរិត ធានាក្នុងការទិញដី និងរត់ការលើឯកសារទិញ លក់ដី និងឯកសារ ផ្ទេរសិទ្ធិកាន់កាប់ ឲ្យបានសម្រេចស្របតាមច្បាប់ លើដីស្រែប្រាំងរបស់ប្រជាពលរដ្ឋ ០៨គ្រួសារ មានទំហំ ៧,៨៧ ហិចតា ទៅឲ្យដើមបណ្ដឹងឈ្មោះ [redacted] ភារម្យ ភេទប្រុស អាយុ ៤៥ឆ្នាំ ក្រោយពីការធានា និងសន្យារួចមក ឈ្មោះ [redacted] ភារម្យ ក៏បានឲ្យឈ្មោះ [redacted] បូរ៉ា ជាអ្នករត់ការឯកសារទាំងអស់ដើម្បីទិញដីខាងលើពីប្រជាពលរដ្ឋ។ ដើម្បីបោកបញ្ឆោតទារប្រាក់ពីឈ្មោះ [redacted] ភារម្យ ឈ្មោះ [redacted] បូរ៉ា បានព្យាយាមរត់ការយកឯកសារដែលមានភាពមិនប្រក្រតីមួយចំនួន ដូចជាកិច្ចសន្យាលក់ផ្ដាច់របស់ប្រជាពលរដ្ឋទាំង ០៨ គ្រួសារ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ ប៉ុន្តែបែរជា កិច្ចសន្យាទទួលប្រាក់កក់ទៅឲ្យប្រជាពលរដ្ឋនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ទៅវិញ ហើយឈ្មោះ [redacted] បូរ៉ា បានទទួលស្គាល់ថា ខ្លួនពិតជាបានទទួលប្រាក់កក់ និងប្រាក់បង់ជាដំណាក់កាលជាហូរហែរសរុបចំនួន ៦៩,៥០០ (ប្រាំមួយម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លាអាមេរិក ពីឈ្មោះ [redacted] ភារម្យ ពិតប្រាកដមែន។ បន្ទាប់ពីការរត់ការឯកសារទាំងនោះ ឈ្មោះ សែម បូរ៉ា បានយកឯកសារថតចម្លងទៅអោយឈ្មោះ [redacted] ភារម្យ ដែលឯកសារនេះ ១-កិច្ចសន្យាលក់ផ្ដាច់ ២-លិខិតផ្ទេរសិទ្ធិកាន់កាប់ និងប្រើប្រាស់ដី ៣-សមាភាពចូលរួមវាស់វែងដី និង ៤-លិខិតបញ្ជាក់ ដោយឯកសារទាំងអស់សុទ្ធតែជាឯកសារថតចម្លងពុំត្រឹមត្រូវស្របតាមច្បាប់ឡើយ។ នៅពេលទទួលប្រាក់នេះហើយ ឈ្មោះ [redacted] បូរ៉ា មិនបានបន្តរត់ការឯកសារឲ្យឈ្មោះ [redacted] ភារម្យ ដើម្បីឲ្យបានស្របតាមច្បាប់ឡើយ ប៉ុន្តែបែរជានិយាយជាមួយប្រជាពលរដ្ឋទាំង ៨គ្រួសារឲ្យលក់ដីស្រែប្រាំងនេះឲ្យទៅឈ្មោះ [redacted] សំអាត ភេទប្រុស អាយុ៣៨ឆ្នាំ និងឈ្មោះ [redacted] សុខឃៀង ភេទប្រុស អាយុ៣៦ឆ្នាំ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ និងបានទទួលប្រាក់បន្តបន្ទាប់គ្រប់ចំនួន ១៣៦៦១៤ (ដប់បីម៉ឺនមួយពាន់ប្រាំមួយរយដប់បួន) ដុល្លាអាមេរិក ដោយមានលោកមេឃុំ [redacted] ឆេងលាង ដដែល ជាអ្នកចុះហត្ថលេខាឲ្យ ប៉ុន្តែ

Scanned with CamScanner

ឯកសារនៃការលក់ផ្តាច់ និងការផ្ទេរសិទ្ធិកាន់កាប់ គឺមិនមានភាពត្រឹមត្រូវតាមច្បាប់ឡើយ ដូចគ្នាទៅនឹងឯកសារ ដែលឈ្មោះ [redacted] បូរ៉ា បានវត់ការឲ្យឈ្មោះ [redacted] ភារម្យ ដែរជាហេតុនាំឲ្យឯកសារទាំងនេះមិនអាចយកទៅប្រើប្រាស់បាន ទើបធ្វើឲ្យដើមបណ្តឹងឈ្មោះ [redacted] ភារម្យ ព្រមទាំងឈ្មោះ [redacted] សំអាត និងឈ្មោះ [redacted] សុខឃៀង ដាក់ពាក្យបណ្តឹងឈ្មោះ [redacted] បូរ៉ា តែម្តង។

-បានឃើញ ដីកាដំណោះស្រាយលេខ ៤៨២ "ដ.ស" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-លើកលែងការចោទប្រកាន់លើឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ១៦ ឃុំកំពង់លែង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ទីលំនៅសព្វថ្ងៃផ្ទះ [redacted] រាជធានីភ្នំពេញ មុខរបរអ្នកសារពត៌មាន កំរិតវប្បធម៌បរិញ្ញាបត្រគ្រប់គ្រងប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ពីបទ៖ ឆបោក ប្រព្រឹត្តនៅភូមិចុង ឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម ក្នុងអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៦ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភារម្យ ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៧ សស ក្រ.VII "ធ" ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភារម្យ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២-តម្កល់ដីកាដំណោះស្រាយលេខ ៤៨២ ដស ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល ។

៣-សាលដីកានេះប្រកាសជាអសាធារណៈនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ។ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

**នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-យល់ឃើញថា: សភាស៊ើបសួរសាលាឧទ្ធរណ៍សម្រេចតម្កល់ ដីកាដំណោះស្រាយរបស់តុលាការថ្នាក់ក្រោមនោះគឺជាការត្រឹមត្រូវហើយ។



Scanned with CamScanner

## ហេតុដូច្នេះ

## តំណាងមហាអយ្យការស្នើសុំចំពោះតុលាការកំពូលថ្មី:

១-ទទួលបណ្តឹងសាទុក្ខលេខ ២០២ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ភារម្យ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ដោយខុស នឹងគតិច្បាប់។

២-តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ២៧ សស "ក្រ.VII.ក" ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទុកជាបានការដដែល។

+ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ភារម្យ ឆ្លើយខ្ញុំបាទអាយុ ៤៧ ឆ្នាំ មូលហេតុខ្ញុំប្តឹងសាទុក្ខមកនេះ គឺឈ្មោះ [redacted] បូរ៉ា បានឆបោកខ្ញុំបាទហើយសាលាដំបូង ក៏ដូចសាលាឧទ្ធរណ៍បានលើកលែងចោទប្រកាន់បានជាខ្ញុំមិនសុខចិត្ត ព្រោះ[redacted]បូរ៉ា គាត់ថាមុខរបរគាត់ជាអ្នកសារពត៌មានហើយមានដី ៧ហិចតាយកមកលក់អោយខ្ញុំៗក៏កក់លុយគាត់ ៨០០០ដុល្លា បន្ទាប់មកទៀតថែម ២០០០ដុល្លា ទៀតគ្រប់ ១០០០០ដុល្លា ហើយក៏បានកក់បន្តបន្ទាប់ថែមទាំងបូក ២សន្លឹកទៀតមានរូបថតស្រាប់ ពេលនោះខ្ញុំទាមទារអោយគាត់ចុះទៅវាស់វែងមានជំនាញ សុរិយោដីច្បាស់លាស់ដល់ពេលទៅចុះគ្មានជំនាញ ទេមានតែគ្នាឯង ខ្ញុំអត់ទុកចិត្តលោកមេភូមិ ក៏មិនព្រមចុះហត្ថលេខាព្រោះគ្មានប្លង់ត្រឹមត្រូវពេលគាត់ទារលុយខ្ញុំទៀតខ្ញុំឈប់ឲ្យគាត់ព្រោះប្លង់ដីមិនពិតប្រាកដ ។

សំណូមពរ សុំផ្តន្ទាទោសឈ្មោះ[redacted]បូរ៉ា ទៅតាមច្បាប់

+លោកមេធាវី [redacted]ស៊ីដាណា ការពារអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ភារម្យ ធ្វើសេចក្តីសន្និដ្ឋានថា

រឿងហេតុកូនក្តីខ្ញុំមានទំនាក់ទំនងទិញដីជាមួយឈ្មោះ [redacted] បូរ៉ា ហើយឈ្មោះ [redacted]បូរ៉ា នេះគាត់ជាអ្នកសារពត៌មានបានបញ្ចុះបញ្ចូលអោយកូនក្តីខ្ញុំទិញដីគាត់ ក្នុងរឿងនេះមានឯកសារភស្តុតាង លក់ផ្តាច់ពេលកូនក្តីខ្ញុំអោយលុយទៅ [redacted] បូរ៉ា គាត់បានអោយ [redacted] បូរ៉ា ចាំគាត់ទៅមើលដី តាមពិតគ្មានដីទេ គឺកូនក្តីខ្ញុំចាញ់បោកសែម បូរ៉ា។

សំណូមពរ មេត្តាលុបសាលដីការបស់សាលាឧទ្ធរណ៍សុំចោទប្រកាន់លើឈ្មោះ[redacted]បូរ៉ា តាមផ្លូវច្បាប់ ។

+លោកមេធាវី [redacted] ចណ្ណារិទ្ធិ ការពារជនត្រូវចោទឈ្មោះ [redacted] បូរ៉ា ធ្វើសេចក្តីសន្និដ្ឋានថា ការចោទប្រកាន់របស់ដើមបណ្តឹងឈ្មោះ [redacted]ភារម្យ ថាកូនក្តីខ្ញុំបានប្រព្រឹត្តបទល្មើស ឆបោក នោះគឺពុំត្រឹមត្រូវទាល់ តែសោះ ពីព្រោះទឹកប្រាក់ ដែលកូនក្តីខ្ញុំបានទទួលយកមកគឺយកទៅកក់ប្រាក់និងទូទាត់រហូតដល់ចេញជាលិខិតស្នាមមានការព្រមព្រៀងពីសំណាក់អ្នកលក់ហើយមានការទទួលស្គាល់ពីអាជ្ញាធរ ដូចអ្វីដែលបានព្រមព្រៀងជាមួយ [redacted] ភារម្យ យ៉ាងពិតប្រាកដ ហេតុនេះហើយទើប សាលាដំបូងខេត្តកំពង់ចាម ធ្វើសេចក្តីសម្រេចចេញដីកាដំណោះស្រាយលេខ ៤៨២ ចស ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩ ដោយសម្រេចលើកលែងការចោទប្រកាន់លើកូនក្តីខ្ញុំបាទឈ្មោះ[redacted]បូរ៉ា ពីបទ ឆបោក ប្រព្រឹត្តនៅភូមិចុង ឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីអំឡុងឆ្នាំ ២០១៨ នេះបន្ទាប់មកលោក [redacted]ភារម្យ បានប្តឹងឧទ្ធរណ៍លើដីកា ដំណោះស្រាយនេះទៀត ប៉ុន្តែបណ្តឹងឧទ្ធរណ៍

Scanned with CamScanner

របស់លោកនៅតែសាលាឧទ្ធរណ៍ធ្វើការសម្រេចច្រានចោលនិងតម្កល់ដីកាដំណោះស្រាយនេះ ទុកជាបានការដដែលដោយសំអាងហេតុនិងមូលហេតុ ដែលកូនក្តីខ្ញុំបានប្រព្រឹត្តនោះគឺមិនមែនជាបទល្មើសឆបោក ដូចការចោទប្រកាន់នោះទេ។

ហេតុដូចនេះខ្ញុំបាទស្នើសុំអោយតុលាការមេត្តាពិនិត្យ និងសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានរបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២០២ ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណី [redacted] ការម្យ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា តាមខ្លឹមសារនៃលិខិតសារណាការពារ ក៏ដូចជានាពេលសវនាការនៅតុលាការកំពូលនេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាមេធាវីដែរ បានសុំឱ្យតុលាការកំពូលបដិសេធសាលដីកាព្រហ្មទណ្ឌលេខ ២៧ សស ក្រ.VII "ធ" ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ចោលជាអសារបង់ និង សុំឱ្យចោទប្រកាន់ និង ផ្តន្ទាទោសជនត្រូវចោទ [redacted] បូរ៉ា ពីបទ ឆបោក តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ដោយសំអាងថា ឈ្មោះ [redacted] បូរ៉ា ជាតំណាងឱ្យប្រជាពលរដ្ឋ ៨ គ្រួសារ ដែលមានដីលក់ឱ្យកូនក្តីខ្លួន នៅពេលដែលកូនក្តីខ្លួនបានប្រគល់ប្រាក់ជាបន្តបន្ទាប់ឱ្យឈ្មោះ [redacted] បូរ៉ា រហូតដល់ចំនួន ៦៩ ៥០០ (ប្រាំមួយម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លាអាមេរិក នៅខ្វះតែចំនួន ៣៦ ៨៩០,៦៩ (បីម៉ឺនប្រាំពាន់ប្រាំបីរយកៅសិប កៀសហុកសិបប្រាំបួន) ដុល្លាអាមេរិក ទៀត ហើយត្រូវប្រគល់គ្រប់ចំនួន នៅពេលដែលឈ្មោះ [redacted] បូរ៉ា រត់ការកាត់ឈ្មោះចប់សព្វគ្រប់មកឱ្យកូនក្តីខ្លួន ប៉ុន្តែក្រោយមក ឈ្មោះ [redacted] បូរ៉ា ព្យាយាមគេចវេសមិនព្រមជួបកូនក្តីខ្លួនជាអ្នកទិញ ទើបដឹងថាឈ្មោះ [redacted] បូរ៉ា បានឆបោក យកប្រាក់ពីកូនក្តីខ្លួន តែមិនបានយកប្រាក់នេះទៅប្រគល់ឱ្យប្រជាពលរដ្ឋទេនិងបានញុះញង់ឱ្យប្រជាពលរដ្ឋផ្តាច់កិច្ចសន្យាលក់ដីមកឱ្យកូនក្តីខ្លួន ហើយយកដីនេះទៅលក់ឱ្យអ្នកដទៃនោះ តុលាការកំពូល ពិនិត្យលើអង្គហេតុ និង ភស្តុតាងដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនិង នៅចំពោះតុលាការកំពូលនាពេលសវនាការនេះ គឺជាអង្គហេតុទាក់ទងនឹងការមិនគោរពនូវកិច្ចសន្យាទិញលក់ដី ដែលតុលាការអង្គសេចក្តីបានធ្វើការពិនិត្យពិចារណាត្រឹមត្រូវតាមអង្គហេតុ និង គតិច្បាប់រួចហើយ។

Scanned with CamScanner

លើសពីនេះ ដើមបណ្តឹងរដ្ឋប្បវេណី មិនមានភស្តុតាងបញ្ជាក់បង្ហាញដែលគួរឲ្យជឿបានថា ជនត្រូវចោទ បានកិបកេងប្រាក់ថ្លៃទិញដីដែលទទួលបានពីដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាការប្រើល្បិច ឬមធ្យោបាយបោយទុច្ចរិត ដើម្បីឲ្យប្រគល់ប្រាក់ តែគ្មានដីលក់នោះទេ ផ្ទុយទៅវិញ ប្រជាជន ៨គ្រួសារ និងជនត្រូវចោទ ពិតជាមានដីលក់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយទទួលបានប្រាក់ថ្លៃទិញដីនេះ ទើបប្រជាជនទាំងអស់សុខចិត្តធ្វើលិខិតផ្ទេរសិទ្ធិទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្ទាប់ពីមិនទទួលបានប្រាក់តាមពេលវេលាកំណត់ក្នុងកិច្ចសន្យា ប្រជាជន ៨គ្រួសាររំលាយកិច្ចសន្យាលក់ទិញដីចោល ឃើញថា មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ [redacted]ប្តូរ៉ា ពីបទឆបោកឡើយ ហើយការវិនិច្ឆ័យរបស់សភាស៊ើបសួរសាលាឧទ្ធរណ៍ មិនមានកំហុសក្នុងការអនុវត្តច្បាប់ទេ ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៧ សស ក្រVII “ធ” ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

**១-បដិសេធ** បណ្តឹងសាទុក្ខលេខ ២០២ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណី [redacted]ភារម្យ ។

**២-តម្កល់** សាលដីកាព្រហ្មទណ្ឌលេខ ២៧ សស ក្រVII “ធ” ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទុកជាបានការទាំងមូល។

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០២០ ។

Scanned with CamScanner